**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមព្រះតេជៈគម្ពល់លើត្បូង**

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះករុណាថ្លៃវិសេស !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស នៃព្រះរាជពិធីដ៏មហាជ័យមង្គលឧត្តុងឧត្តមប្រសើរថ្លៃថ្លា នាទិវាខួប លើកទី៦ នៃការគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណាថ្លៃវិសេស** ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សូមព្រះរាជវរោកាសរាជានុញ្ញាត សម្ដែងនូវមនោសញ្ចេតនារីករាយជាទីបំផុតថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីសក្ការៈ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យទ្រង់គង់ ព្រះបរមរាជសម្បត្តិ ដើម្បីជាម្លប់ដ៏សុខក្សេមក្សាន្ត ត្រជាក់ត្រជុំរបស់មាតុភូមិអង្គរ សម្រាបវិបុលភាព របស់ប្រជាជនកម្ពុជា និងដើម្បីកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមថ្វាយព្រះពរសព្ទសាធុការ បវរមហាប្រសើរបំផុតចំពោះ **ព្រះករុណាថ្លៃវិសេស** សូមព្រះអង្គ ទ្រង់គង់ នៅក្នុងព្រះបរមរាជសម្បត្តិយូរអង្វែង មានព្រះរាជសុខភាពល្អប្រសើរបរិបូរណ៍ មានព្រះជន្មាយុ យឺនយូរ មានព្រះកាយពលមាំមួន មានព្រះបញ្ញាញាណឈ្លាសវៃ និង សម្រេចបាននូវមហាជោគជ័យ ក្នុងរជ្ជកាលដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ព្រះអង្គ ។

ក្នុងឱកាសដ៏មហាថ្លៃថ្លានេះដែរ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាត សម្ដែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅជាទីបំផុត និង ទឹកចិត្តគោរពកោតស្ញប់ស្ញែងបំផុត ថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ដែលព្រះអង្គទ្រង់បានយកព្រះរាជហឫទ័យទុកដាក់ និង លះបង់ព្រះកាយពលជាប្រចាំ សម្រាប់សុខុមាលភាពរបស់ប្រជាជនកម្ពុជាគ្រប់ទិសទី ពិសេសសម្រាប់ ប្រជាជនងាយរងគ្រោះ ។ ទន្ទឹមនឹងនេះ **ព្រះករុណាថ្លៃវិសេស** ព្រះអង្គទ្រង់បានបំពេញ ព្រះរាជបេសកកម្មជាតិ ក្នុងកិច្ចការទំនាក់ទំនងជាមិត្តភាពជាមួយបណ្ដាប្រទេសនានានិងសហប្រតិបត្តិការ អន្តរជាតិ ហើយព្រះអង្គទ្រង់បានលើកតម្កើងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាឡើងខ្ពស់ត្រដែត នៅលើឆាកអន្តរជាតិ ។ ដោយព្រះរាជតេជៈបារមីដ៏ឧត្តុង្គឧត្តមរបស់ **ព្រះករុណាថ្លៃវិសេស**

ព្រះរាជាណាចក្រកម្ពុជា រក្សាបាននូវសន្តិភាព និង ឯកភាពទឹកដី រក្សាបាននូវស្ថេរភាពនយោបាយ ធានាបាននូវសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម និង ជាពិសេស រក្សាបាននូវលំនឹងជីវភាពរបស់ប្រជាជន និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ទោះបីព្រះរាជាណាចក្រកម្ពុជាទទួលរងនូវឥទ្ធិពលនៃវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសាកលលោក ចាប់តាំងពីចុងឆ្នាំ ២០០៨ និង ក្នុងឆ្នាំ ២០០៩ ក៏ដោយ ។

ដើម្បីតបស្នងទៅនឹងព្រះគុណូបការៈដ៏មហាធំធេងនេះ របស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាចិត្តមិនខ្លាចនឿយហត់ក្នុងការបំពេញភារកិច្ចរបស់ទូលព្រះបង្គំយើងខ្ញុំ តាមមុខសញ្ញារៀងៗខ្លួន ដោយប្រកាន់ខ្ជាប់នូវសីលធម៌ស្មោះត្រង់ អភិបាលកិច្ចល្អ និងដោយធ្វើឱ្យមានជាប្រចាំនូវប្រសិទ្ធភាព និង ប្រសិទ្ធផលការងារ ដើម្បីដង្ហែតាមព្រះរាជកិច្ច និង ព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាថ្លៃវិសេស** ក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ ប្រយោជន៍សម្រាប់វិបុលសុខ សុខុមាលភាពរបស់ប្រជាជនកម្ពុជា និង ភាពរុងរឿង និងខ្ពស់ត្រដែតនៃព្រះរាជាណាចក្រកម្ពុជា ។

ទូលព្រះបង្គំយើងខ្ញុំ សូម **ព្រះករុណាថ្លៃវិសេស** ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ព្រមទាំងមនោសញ្ចេតនាគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុត និង ភក្តីភាពឥតងាករេរបស់ទូលព្រះបង្គំយើងខ្ញុំ

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១០

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**